# ខ្មែរប្រែថាក្រៀម

| | |
|---|---|
| បើយើងនិងពោលពាក្យថាខ្មែរ | គ្រប់គ្នាដឹងដែរថាក្រៀមក្សាន្ត |
| តែបើសង្កេតហើយតាមដាន | ពាក្យថាក្រៀមក្សាន្តដូចនៅឆ្ងាយ។ |
| តាំងពីកើតមកដល់ឥឡូវ | និយាយចំទៅដល់វែងឆ្ងាយ |
| លើកយកខ្លីៗមកបរិយាយ | ជូនខ្មែរទាំងឡាយគ្រាន់ពិចារណ៍។ |
| ខ្មែរក្រោមខ្មែរកណ្តាលនិងខ្មែរលើ | បើយើងគិតមើល៍ពង្សាវតារ |
| គឺខ្មែរតែមួយពូជដូនតា | មានជាប់សាវតារពីបុព្វេ។ |
| ខ្មែរក្រោមបាត់សិទ្ធិជាម្ចាស់ដី | បនពាលអប្រិយវាប្លន់កេរ្តិ៍ |
| ខ្មែរក្រោមរងទុក្ខឈឺផ្សាទ្វេ | រស់លើដីកេរ្តិ៍បាត់ម្ចាស់ការ។ |
| ខ្មែរក្រោមរស់នៅលើដីខ្លួន | ក្រោមរបបយួនជនផ្តាច់ការ |
| យួនបំផ្លាញជាតិនិងសាសនា | លើដីដូនតាកម្ពុជាក្រោម។ |
| រីឯខ្មែរលើស្ទើរបាត់ឈ្មោះ | សៀមវាសាបព្រួសដោយវប្បធម៌ |
| ខ្លះរស់ភ្លេចខ្លួនខំត្រេកអរ | ព្រោះមានវប្បធម៌ស្រៀកៗគ្នា។ |
| ដីខ្មែរសៀមយកក៏មិនតិច | ប្រាសាទរំលេចក្បាច់ល្អជា |
| យួនកើតសៀមលិចវាដូចគ្នា | ចង់លេបកម្ពុជាឲ្យបាត់សូន្យ។ |
| ឯខ្មែរកណ្តាលក្រុងភ្នំពេញ | គេថាចំណេញដីមកខ្លួន |
| វាស់វែងព្រំដែនតាមបញ្ជាយួន | ខំលាក់បំពួនយ៉ាងកំសាក។ |
| ខ្មែរស្នេហាជាតិឃើញតែស្លាប់ | សង្គមប្រើច្បាប់បុគ្គលម្នាក់ |
| ពុករលួយដល់ឆ្អឹងខំលបលាក់ | ខ្មែរក្រតោកយ៉ាកស្រែកពេញស្រុក។ |
| កំណាព្យបែបខ្លីលាសិនហើយ | បងប្អូនខ្មែរអើយកុំភ្លេចស្រុក |
| ខំជួយឃឹតយោងឲ្យខ្ពស់មុខ | ពាក្យខ្មែរប្រែថាសុខក្រៀមក្សាន្ត។ |

គឹម ហឿង សុវណ្ណ

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែពិសាខ ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី០៣ ខែឧសភា គ.ស.២០១២ (ចូលព.ស.២៥៥៦នៅថ្ងៃអាទិត្យ ០១រោច ខែពិសាខ ត្រូវនឹងថ្ងៃទី០៦ ឧសភា)